# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខៈ ០៦៩/១៤ ស.ខ.ក.ក.

**គោរពជូន**

**ឯកឧត្តម ប៉ា សុជាតិវង្ស**

**អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ**

**កម្មវត្ថុៈ ជូនដំណឹងស្តីអំពីការធ្វើបាតុកម្មចំនួន៥ថ្ងៃ គឺថ្ងៃទី០៤ ដល់ ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៤**

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា សហគមន៍ខ្មែរកម្ពុជាក្រោម និង សម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ នឹងរៀបចំធ្វើបាតុកម្មចំនួន ៥ថ្ងៃជាប់គ្នា គឺថ្ងៃទី០៤ ដល់ ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៤ ចាប់ពីម៉ោង ០៨ព្រឹក ដល់ ម៉ោង ០៥ល្ងាច ជារៀងរាល់ថ្ងៃ ដែលមានមនុស្សចូលរួមប្រមាណ ២០០០នាក់។

ថ្ងៃទី០៤ ជួបជុំគ្នានៅទីលានប្រជាធិបតេយ្យ រួចក្បួនបាតុកម្មដង្ហែទៅតាមផ្សារនានាបិទខិតប័ណ្ណ។ បន្ទាប់មក ក្បួនបាតុកម្មនឹងដង្ហែទៅមុខស្ថានទូតវៀតណាម សម្តែងមតិរហូតម៉ោង ៥ល្ងាចរំសាយ។

ថ្ងៃទី០៥ ជួបជុំគ្នានៅទីលានប្រជាធិបតេយ្យ រួចក្បួនបាតុកម្មដង្ហែទៅតាមផ្សារនានាបិទខិតប័ណ្ណ។ បន្ទាប់មក ក្បួនបាតុកម្មនឹងដង្ហែទៅមុខស្ថានទូតវៀតណាម សម្តែងមតិរហូតម៉ោង ៥ល្ងាចរំសាយ។

ថ្ងៃទី០៦ ជួបជុំគ្នានៅទីលានប្រជាធិបតេយ្យ រួចដង្ហែញត្តិទៅរដ្ឋសភា។ ក្រោយពីដាក់ញត្តិរួច ក្បួនបាតុកម្មនឹងដង្ហែទៅមុខស្ថានទូតវៀតណាម សម្តែងមតិរហូតម៉ោង ៥ល្ងាចរំសាយ។

ថ្ងៃទី០៧ ជួបជុំគ្នានៅទីលានប្រជាធិបតេយ្យ រួចដង្ហែញត្តិទៅវិមានសន្តិភាព។ ក្រោយពីដាក់ញត្តិរួច ក្បួនបាតុកម្មនឹងដង្ហែទៅមុខ ស្ថានទូតវៀតណាម សម្តែងមតិរហូតម៉ោង ៥ល្ងាចរំសាយ។

ថ្ងៃទី០៨ ជួបជុំគ្នានៅទីលានប្រជាធិបតេយ្យ រួចដង្ហែញត្តិទៅស្ថានទូតបារាំង។ បន្ទាប់មកទៅឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា។ ក្រោយពីដាក់ញត្តិរួច ក្បួនបាតុកម្មនឹងដង្ហែទៅមុខស្ថានទូតវៀតណាម សម្តែងមតិរហូតម៉ោង ៥ល្ងាចរំសាយ។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាជ្រាប និងជួយចាត់វិធានការការពារសន្តិសុខសណ្តាប់ធ្នាប់ដល់ក្បួនបាតុកម្ម របស់យើងខ្ញុំ ដោយអនុគ្រោះ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកញ្ញា ព.ស.២៥៥៨ គ.ស.២០១៤

នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

សហគមន៍ខ្មែរកម្ពុជាក្រោម * THE KHMER KAMPUCHEA KROM COMMUNITY *

ថាច់ សេដ្ឋា

---

ទីស្នាក់ការៈ ផ្ទះលេខ ៧២ ផ្លូវលេខ ៤២៦A ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី
ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា; ទូរស័ព្ទលេខៈ (៨៥៥) ៧៨ ៨៩៨ ៨៨២ / ៩៣ ៤៧ ៤៧ ០៦
អាសយដ្ឋានអ៊ីមែល: thachsetha13@gmail.com, kkcpressoffice@yahoo.com
Website: khmerkromngo.org; Facebook: khmerkkcommunity